ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី រៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ៤នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៤នាក់** ដូចខាងក្រោមៈ

**(១)** ពលការិនី ***ព.ស.វ*** អាយុ៤០ឆ្នាំ មកពីខេត្តស្វាយរៀង បានទៅធ្វើការងារតាមផ្ទះ នៅម៉ាឡេស៊ី ពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា ។ ដោយធ្វើការលំបាក ពលការិនីបានទៅស្ថានទូតនៅខែកក្កដា ឆ្នាំ២០១៦ ស្នើសុំជួយទាមទារប្រាក់ខែដែលនៅសល់ពីថៅកែ និងជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ តាមសំណូមពររបស់ស្ថានទូត ថៅកែរបស់ពលការិនី បានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ និងលិខិតឆ្លងដែនដល់នាងវិញ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

**(២)** ពលការិនី **អ៊.ស.ម** អាយុ២៦ឆ្នាំ មកពីខេត្តកំពង់ចាម បានទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៦ ស្នើសុំស្ថានទូតទាមទារប្រាក់ខែពីថៅកែ និងជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានសហការជាមួយអាជ្ញាធរម៉ាឡេស៊ី ស្វែងរកថៅកែរបស់ពលការិនី ឲ្យមកដោះស្រាយ។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ទើបថៅកែរបស់នាង បានយល់ព្រមប្រគល់ប្រាក់ខែដល់នាង តាមសំណូមពររបស់ស្ថានទូត។

**(៣)** ពលការិនី **ច.ផ.ល** អាយុ២៩ឆ្នាំ មកពីរាជធានីភ្នំពេញ បានទៅធ្វើការងារតាមផ្ទះនៅម៉ាឡេស៊ី ពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា ។ នាងបានទទួលប្រាក់ខែគ្រប់ចំនួន ប៉ុន្តែដោយសារចង់មកផ្ទះវិញ នាងបានទៅស្ថានទូតនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជា។

**(៤)** ពលការិនី **ទ.ច.រ** អាយុ២១ឆ្នាំ មកខេត្តតាកែវ បានទៅម៉ាឡេស៊ី ធ្វើការខុសច្បាប់នៅហាង Game Internet ពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៥ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ នាងបានទៅស្ថានទូតនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ សុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ នាងពុំទាមទារប្រាក់ខែដែលនៅសល់ទេ ពីព្រោះថៅកែរបស់នាងត្រូវបានអាជ្ញាធរម៉ាឡេស៊ីចាប់ខ្លួន ពីបទបើកអាជីវកម្ម Game Internet ខុសច្បាប់។

ពលការិនីទាំង**៤នាក់** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៤** ខែ**វិច្ឆិកា** ឆ្នាំ**២០១៦** វេលាម៉ោង**០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ **AK536** ។ អំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្ដល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់ពលការិនីទាំង**៤នាក់** ផងដែរ៕

ភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ